# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៧៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## លក្ខន្តិកៈមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា ៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពី ការបង្កើតរាជបណ្ឌិតសភាកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៧/៣១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីលក្ខណៈសម្បត្តិ មុខងារ ភារកិច្ច និងសិទ្ធិ របស់មន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ២ .-

អនុក្រឹត្យនេះអនុវត្តចំពោះមន្ត្រីស្រាវជ្រាវជាមន្ត្រីមុខងារសាធារណៈ ក្របខណ្ឌប្រភេទ ក ដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ហើយកំពុងបំពេញមុខងារស្រាវជ្រាវនៅរាជបណ្ឌិតសភាកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ២

## លក្ខខណ្ឌ និងលក្ខណៈសម្បត្តិនៃមន្ត្រីស្រាវជ្រាវ

មាត្រា ៣ .-

មន្ត្រីស្រាវជ្រាវជាមន្ត្រីដែលមានឧបនិស្ស័យជាអ្នកសិក្សាស្រាវជ្រាវ ទៅតាមមុខជំនាញរបស់ខ្លួន នៅគ្រប់ផ្នែកនៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៤ .-

លក្ខណៈសម្បត្តិចូលជាមន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជាមានដូចខាងក្រោម ៖

១- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ

២- កំពុងបំពេញការងារស្រាវជ្រាវតាមផែនការ

៣- មានលទ្ធផលស្រាវជ្រាវតាមផែនការ

៤- មានប្រវត្តិការងារល្អ

៥- មានសីលធម៌រស់នៅល្អ

លក្ខណៈសម្បត្តិផ្សេងៗទៀតនឹងត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីស្រាវជ្រាវ ។

មាត្រា ៥ .-

លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវម្នាក់ៗ ត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងវិទ្យាស្ថាន និងដោយក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ហើយត្រូវទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៦ .-

ក្រោយពេលចូលជាមន្ត្រីស្រាវជ្រាវហើយ មន្ត្រីស្រាវជ្រាវម្នាក់ៗត្រូវបំពេញលក្ខខណ្ឌ ដើម្បីរក្សាស្ថានភាពរបស់ខ្លួនដូចខាងក្រោម ៖

១- អនុវត្តការស្រាវជ្រាវរបស់ខ្លួន តាមផែនការដែលបានកំណត់

២- មានលទ្ធផលស្រាវជ្រាវ តាមផែនការដែលបានកំណត់

៣- ចូលរួមប្រជុំទៀងទាត់ក្នុងការងារស្រាវជ្រាវ តាមផ្នែកជំនាញរបស់ខ្លួន

៤- មានសីលធម៌វិជ្ជាជីវៈជាអ្នកស្រាវជ្រាវ ។

មាត្រា ៧ .-

លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវអាចត្រូវបញ្ចប់វិញបាន ទៅតាមករណីជាក់ស្តែង ផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រងវិទ្យាស្ថាន និងរបស់ក្រុមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិតសភាកម្ពុជា ។

បែបបទនៃការវាយតម្លៃ និងការបញ្ចប់លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវ និងការវាយតម្លៃស្នាដៃស្រាវជ្រាវ មានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់មន្ត្រីស្រាវជ្រាវ ។

មាត្រា ៨ .-

ក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ធ្វើការវាយតម្លៃលក្ខណៈសម្បត្តិមន្ត្រីស្រាវជ្រាវ ក្នុងផែនការដែលបានកំណត់រៀងរាល់ ៦ខែម្តង ។

មាត្រា ៩ .-

មន្ត្រីដែលត្រូវបានបញ្ចប់លក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវ ត្រូវអស់សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្រាវជ្រាវ ចាប់ពីកាលបរិច្ឆេទចេញប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិនៃរាជបណ្ឌិតសភាកម្ពុជា ។

រយៈពេលចេញប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវកំណត់យ៉ាងយូរ ១ខែ បន្ទាប់ពីរបាយការណ៍វាយតម្លៃរបស់ក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ។

## ជំពូកទី ៣
## មុខងារ និងភារកិច្ចរបស់មន្ត្រីស្រាវជ្រាវ

មាត្រា ១០ .-

មន្ត្រីស្រាវជ្រាវមានមុខងារចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ក្នុងវិស័យស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ តាមរយៈកម្លាំងបញ្ញាញាណរបស់ខ្លួន ដើម្បីក្លាយទៅជាធនធានមនុស្សដែលមានសមត្ថភាពក្នុងមុខជំនាញ នៅពេលបច្ចុប្បន្ន និងទៅអនាគត ។

មាត្រា ១១ .-

ភារកិច្ចរបស់មន្ត្រីស្រាវជ្រាវ ៖

១- អនុវត្តការសិក្សាស្រាវជ្រាវ ដើម្បីបង្កើតស្នាដៃរួម និងផ្ទាល់ខ្លួន

២- អនុវត្តផែនការការងារ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានគំនិតផ្តួចផ្តើមក្នុងវិស័យស្រាវជ្រាវ

៣- ចូលរួមប្រជុំតាមផ្នែកជំនាញ ចូលរួមក្នុងសិក្ខាសាលា សន្និសីទ គម្រោងស្រាវជ្រាវជាតិ និងអន្តរជាតិ

៤- ចូលរួមក្នុងសកម្មភាពបង្រៀន និងការផ្លាស់ប្តូរបទពិសោធន៍

៥- ចូលរួមក្នុងការរៀបចំគម្រោងផែនការស្រាវជ្រាវ

៦- ចូលរួមក្នុងការពិភាក្សា វាយតម្លៃលទ្ធផលនៃការស្រាវជ្រាវ

៧- សហការ បើកទូលាយក្នុងកិច្ចការស្រាវជ្រាវ

៨- ទទួលខុសត្រូវចំពោះលទ្ធផលស្រាវជ្រាវ ដែលកំពុងធ្វើការស្រាវជ្រាវ និងដែលពុំទាន់ធ្វើការផ្សព្វផ្សាយ ។

ស្នាដៃស្រាវជ្រាវ ការចូលរួមប្រជុំក្នុងការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រផ្សេងៗ ជាលក្ខខណ្ឌចាំបាច់សម្រាប់មន្ត្រីស្រាវជ្រាវម្នាក់ៗ ។

មាត្រា ១២ .-

ផ្នែកជំនាញនីមួយៗនៃរាជបណ្ឌិតសភាកម្ពុជា មានភារកិច្ចទទួលខុសត្រូវអំពីការបង្កើតស្នាដៃ ការវាយតម្លៃស្នាដៃ ការចូលរួមប្រជុំ ក្នុងការងារស្រាវជ្រាវវប្បធម៌ និងវិទ្យាសាស្ត្រ របស់មន្ត្រីស្រាវជ្រាវម្នាក់ៗ ដើម្បីធានានូវលក្ខណៈសម្បត្តិជាមន្ត្រីស្រាវជ្រាវ និងសិទ្ធិផ្សេងៗរបស់មន្ត្រីស្រាវជ្រាវ ។

## ជំពូកទី ៤
## សិទ្ធិរបស់មន្ត្រីស្រាវជ្រាវ

មាត្រា ១៣ .-

មន្ត្រីស្រាវជ្រាវដែលទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានទទួលនូវប្រាក់បំណាច់ស្រាវជ្រាវ ដូចមានកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣១០ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីប្រាក់បំណាច់ស្រាវជ្រាវរបស់សមាជិកបណ្ឌិតសភា និងមន្ត្រីស្រាវជ្រាវ នៃរាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ១៤ .-

លទ្ធផលនៃការស្រាវជ្រាវត្រូវយកធ្វើជាមូលដ្ឋានសម្រាប់ការតម្លើងថ្នាក់ ឬឋានន្តរស័ក្តិ ក្នុងការផ្តល់គ្រឿងឥស្សរិយយស និងការតម្លើងកម្រិតប្រាក់បំណាច់ស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវ តាមនីតិវិធីជាធរមានក្នុងមុខងារសាធារណៈ។

លទ្ធផលនៃការស្រាវជ្រាវរបស់មន្ត្រីស្រាវជ្រាវដែលស្ថិតក្នុងផែនការរបស់រាជបណ្ឌិតសភាកម្ពុជា ជាកម្មសិទ្ធិរបស់រដ្ឋ ប៉ុន្តែមន្ត្រីស្រាវជ្រាវអាចទទួលបាននូវកម្រៃកម្មសិទ្ធិបញ្ញាពីស្នាដៃរបស់ខ្លួន។

មាត្រា ១៥ .-

ការស្រាវជ្រាវត្រូវបានទទួលការគាំពារពីរដ្ឋក្នុងការការពារកម្មសិទ្ធិបញ្ញា ការបោះពុម្ពផ្សាយ ការចូលទៅកាន់កន្លែងដែលជាកម្មវត្ថុនៃការស្រាវជ្រាវ ការការពារផ្នែកសន្តិសុខ និងសុវត្ថិភាពរបស់មន្ត្រីស្រាវជ្រាវ និងការផ្តល់ធនធានសម្រាប់ការស្រាវជ្រាវ។

មាត្រា ១៦ .-

មន្ត្រីស្រាវជ្រាវត្រូវបានផ្តល់អាទិភាព ក្នុងការបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស ផ្អែកលើលក្ខណៈសម្បត្តិការស្រាវជ្រាវរបស់ខ្លួន និងលក្ខខណ្ឌចាំបាច់ដែលបានបំពេញ។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

មាត្រា ១៧ .-

ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន ក្នុងរយៈពេលយ៉ាងយូរ ២ខែ មន្ត្រីរាជការកំពុងបម្រើការនៅរាជបណ្ឌិតសភាកម្ពុជា ដែលមានសញ្ញាបត្របណ្ឌិត និងបរិញ្ញាបត្រជាន់ខ្ពស់ អាចដាក់ពាក្យសុំចូលជាមន្ត្រីស្រាវជ្រាវបណ្តោះអាសន្ន។

មន្ត្រីដែលចូលជាមន្ត្រីស្រាវជ្រាវបណ្តោះអាសន្ន ហើយទទួលស្គាល់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានសិទ្ធិទទួលប្រាក់បំណាច់ស្រាវជ្រាវ កម្រិត៥។ ក្នុងរយៈពេល ១២ខែ យ៉ាងយូរក្រុមសមាជិកពេញសិទ្ធិនៃរាជបណ្ឌិតសភាកម្ពុជា ត្រូវធ្វើការវាយតម្លៃមន្ត្រីដែលមានលក្ខណៈសម្បត្តិ ដូចមានកំណត់ក្នុងមាត្រា៤ ដើម្បីចូលជាមន្ត្រីស្រាវជ្រាវ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ១៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ១៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានរាជបណ្ឌិតសភាកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ